# សេចក្តីព្រាងអត្ថបទសារពត៌មាន
# លទ្ធផលសរុបកិច្ចប្រជុំពេញអង្គលើកទី៦នៃអ.វ.ត.ក

**ថ្ងៃទី ១១ខែកញ្ញាឆ្នាំ២០០៩**

កិច្ចប្រជុំពេញអង្គនៃអ.វ.ត.កបានបញ្ចប់នៅថ្ងៃនេះ ក្រោយពីបានពិចារណាលើសំណើវិសោធនកម្ម និង អនុម័តលើវិធានផ្ទៃក្នុងរបស់ខ្លួនមួយចំនួន។ វិសោធនកម្មដែលបានអនុមត័ដោយកិច្ចប្រជុំពេញអង្គ ញ៉ាំងឲ្យដំណើរការនីតិវិធីកាន់តែមានប្រសិទ្ធិភាពទាក់ទងទៅនឹងបញ្ហាជាច្រើន រួមមានវិធានការការពារជនរងគ្រោះ និង សាក្សី និងវិធាននៃភស្តុតាង ក៏ដូចជា ការអនុម័ត ឬ ការបង្កើតវិធានការដើម្បីជំរុញដំណើរការនីតិវិធីជំនុំជម្រះឲ្យកាន់តែលឿនថែមទៀត។

កិច្ចប្រជុំពេញអង្គបានបោះឆ្នោតគាំទ្រសំណើដែលស្នើដោយគណៈកម្មាធិការនិតិវិធី និងវិធានផ្ទៃក្នុង ដើម្បីធ្វើការកែសម្រួលទស្សនៈទាន នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ ការកែសម្រួលទស្សនៈទាននេះ ត្រូវបានតាក់តែងឡើង ដើម្បីតំរូវទៅតាមលក្ខខណ្ឌនៃឧក្រិដ្ឋកម្មទ្រង់ទ្រាយធំ និងបរិបទជាក់ស្តែងរបស់ប្រទេសកម្ពុជា និងដើម្បីធានាថាតំណើរការនីតិវិធីរបស់អ.វ.ត.ក ឆ្លើយតបទៅនឹងការរំពឹងទុករបស់ជនរងគ្រោះឲ្យបានកាន់តែពេញលេញថែមទៀត។

វិសោធនកម្មទាំងនេះ ក៏នឹងជួយលើកកំពស់ប្រសិទ្ធិភាពក្នុងការរៀបចំកិច្ចដំណើរការជំនុំជម្រះ និង សមត្ថភាពរបស់អ.វ.ត.ក ដើម្បីឈានទៅរកការចេញសាលក្រមនាពេលអនាគត។ កិច្ចប្រជុំពេញអង្គបានសំរេចប្រគល់ភារកិច្ចអោយអនុគណៈកម្មការធ្វើការពង្រាងនូវសំណើវិសោធនកម្មថ្មីៗ ដើម្បីឆ្លុះបញ្ចាំងនូវទស្សនទានដែលបានព្រមព្រៀងគ្នានោះ។

លក្ខណៈពិសេសនៃទស្សនទាន ដែលបានឯកភាពដោយកិច្ចប្រជុំពេញអង្គ សំរាប់ដំណាក់កាលជំនុំជម្រះ និងឧទ្ធរណ៍ រួមមាន:

- មានបណ្ដឹងតែមួយសំរាប់ការទាមទារសំណងផ្លូវចិត្ត និងសមូហភាពត្រូវបានបង្កើតឡើងសំរាប់ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ហើយដែលដើមបណ្ដឹងរដ្ឋប្បវេណីទាំងនោះត្រូវបង្កើតជាក្រុមសមូហភាពតែមួយប៉ុណ្ណោះ។
- ដើមបណ្ដឹងរដ្ឋប្បវេណីដែលច្របាច់បញ្ចូលគ្នាជាក្រុមសមូហភាពនោះ នឹងត្រូវតំណាងដោយ សហមេធាវីនាំមុខមួយ ដែលគាំទ្រដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។
- បើជាការចាំបាច់ បង្កើតនូវនីតិវិធីពិសេសៗជាច្រើនទៀត ដើម្បីដោះស្រាយរាល់វិវាទផលប្រយោជន៍ដែលអាចកើតមាន។

កិច្ចប្រជុំពេញអង្គបានសំរេច និងអនុម័តនូវទម្រង់បំពេញបន្ថែមនៃការចូលរួមរបស់ជនរងគ្រោះ ដែលនឹងអាចកើតមានឡើងនៅក្រៅដំណើរការនីតិវិធីតុលាការជាផ្លូវការ។ អ.វ.ត.កបានទទួលការផ្ដល់យោបល់ក្នុងន័យស្ថាបនាជាច្រើនពីអង្គភាពជនរងគ្រោះ និង សង្គមស៊ីវិលក្នុងវិស័យនេះ។

គណៈកម្មាធិការនីតិវិធីនិងវិធានផ្ទៃក្នុង នឹងកោះប្រជុំសម្រេចលើសំណើវិសោធនកម្មវិធានផ្ទៃក្នុងទាំងនោះនាពេលក្រោយនៅក្នុងឆ្នាំនេះ។

កិច្ចប្រជុំពេញអង្គមួយដើម្បីពិចារណាលើសំណើវិសោធនកម្មទាំងនេះ ទំនងនឹងត្រូវបានរៀបចំក្នុងចុងខែមករា ឆ្នាំ២០១០។

កិច្ចប្រជុំពេញអង្គបានទទួលពត៏មានថា ការស៊ើបអង្កេតលើសំណុំរឿងលេខ ០០២ ត្រូវបានគេរំពឹងទុកថា នឹងត្រូវបញ្ចប់នៅចុងឆ្នាំ ២០០៩។ ដើម្បីអោយសំណុំរឿងលេខ ០០២ នេះដំណើរការទៅបានល្អ វិធានការមួយចំនួនទាក់ទងទៅនឹងការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានគេអនុម័តជាបន្ទាន់។ វិធានការទាំងនេះរួមមាន:

- ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចទទួលទៀតទេនៅដំណាក់កាលជំនុំជម្រះ។ ជនរងគ្រោះដែលមានបំណងចង់តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ យ៉ាងយូរ (១៥) ថ្ងៃ បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតជូនដំណឹងដល់ភាគីទាំងអស់ អំពីការបញ្ចប់ការស៊ើបសួរតាមផ្លូវតុលាការ។
- ភាគី និងជនរងគ្រោះអាចប្ដឹងឧទ្ធរណ៍នឹងរាល់ដីកាដែលចេញដោយសហចៅក្រមស៊ើបអង្កេតពាក់ពន្ធ័នឹងភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ មិនអាចមានការតវ៉ាចំពោះការទទួលស្គាល់ជាដើមបណ្ដឹងរដ្ឋប្បវេណី នៅដំណាក់កាលជំនុំជម្រះទេ។

វិធានការដែលត្រូវបានពិចារណា និងអនុម័តទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី មិនមានផលប៉ះពាល់ណាមួយឡើយ ទៅលើការជំនុំជម្រះសំណុំរឿងលេខ ០០១ នាពេលបច្ចុប្បន្ននេះ។

ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh